**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣ និងមាត្រា៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា១១ថ្មី នៃព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួល ស្គាល់គុណភាពអប់រំនៃកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

# សម្រេច

**មាត្រាមួយ.-**

មាត្រា៣ មាត្រា៤ មាត្រា៧ និងមាត្រា៨ នៃ អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ឧ.ក) ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

**មាត្រា៣ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** ជាអង្គភាពប្រតិបត្តិ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គលេខាធិការរងមានភារកិច្ចទទួលខុសត្រូវតាមការចាត់តាំងរបស់អគ្គលេខាធិការ ។

**មាត្រា៤ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

១. នាយកដ្ឋាន កិច្ចការទូទៅ

២. នាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ

៣. នាយកដ្ឋាន សហប្រតិបត្តិការ និងព័ត៌មាន

៤. នាយកដ្ឋាន ផែនការ បណ្តុះបណ្តាល និងស្រាវជ្រាវ

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ។ ការបង្កើត និងភារកិច្ចរបស់ការិយាល័យ ត្រូវសម្រេចដោយ **គ.ឧ.ក** តាមសំណើរបស់អគ្គលេខាធិការ ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **គ.ឧ.ក** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៧ថ្មី.-**

នាយកដ្ឋានស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំមានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបង្កើត និងអភិវឌ្ឍស្តង់ដារគុណភាពអប្បបរមា សម្រាប់វាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សា
- រៀបចំបង្កើត និងអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងសម្រាប់មន្ត្រីវាយតម្លៃ
- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន
- រៀបចំការចុះវាយតម្លៃ និងពិនិត្យឡើងវិញ លើដំណើរការទទួលស្គាល់គុណភាពអប់រំនៃកម្មវិធីសិក្សា ដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងគ្រឹះស្ថានឧត្តមសិក្សាទាំងមូល
- លើកសំណើជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា
- ផ្តល់ការពិគ្រោះយោបល់ដល់គ្រឹះស្ថានឧត្តមសិក្សា លើដំណើរការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំផ្តល់ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា
- ធ្វើរបាយការណ៍ស្តីពី សកម្មភាព និង លទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន ។

**មាត្រា៨ថ្មី.-**

នាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាន មានភារកិច្ច ដូចខាងក្រោម ៖

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងប្រទេសនានា ក្នុងការងារទូទៅពាក់ព័ន្ធនឹងការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងស្វែងរកជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ
- គ្រប់គ្រង និងចងក្រងទិន្នន័យព័ត៌មានគ្រប់ប្រភេទ របស់ **គ.ឧ.ក**
- ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលគំហើញ និងព័ត៌មានផ្សេងៗ របស់ **គ.ឧ.ក**
- រៀបចំកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ព័ន្ធនឹងការងាររបស់ **គ.ឧ.ក**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន ។

**មាត្រា៩ថ្មី.-**

នាយកដ្ឋាន ផែនការ បណ្តុះបណ្តាល និងស្រាវជ្រាវ មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សនៃអគ្គលេខាធិការដ្ឋាន លើការងារបច្ចេកទេស ព័ត៌មានវិទ្យា ភាសាបរទេស និងជំនាញឯកទេសពាក់ព័ន្ធផ្សេងទៀត ទាំងក្នុងប្រទេស និង ក្រៅប្រទេស
- រៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីវាយតម្លៃ និង គ្រឹះស្ថានឧត្តមសិក្សា ពាក់ព័ន្ធនឹងយន្តការវាយតម្លៃ ផ្តល់ការទទួលស្គាល់គុណភាពអប់រំ ការរៀបចំអភិវឌ្ឍកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការងារពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំគម្រោងបណ្តុះបណ្តាលផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងលើជំនាញពាក់ព័ន្ធនឹងការធានា និងទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- ធ្វើផែនការយុទ្ធសាស្ត្រ និងសម្របសម្រួលក្នុងការរៀបចំផែនការសកម្មភាពការងារ រយៈពេលខ្លី មធ្យម និង វែង របស់អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** ដើម្បីលើកកម្ពស់និងពង្រឹងគុណភាពអប់រំឧត្តមសិក្សា
- ស្វែងរកជំនួយពីដៃគូអភិវឌ្ឍ ជាតិ និង អន្តរជាតិ ដើម្បីទ្រទ្រង់កម្មវិធីបណ្តុះបណ្តាលនានា
- ពិគ្រោះយោបល់ជាមួយគ្រឹះស្ថានឧត្តមសិក្សានិងស្ថាប័នពាក់ព័ន្ធ អំពីការងារបច្ចេកទេស និងក្របខ័ណ្ឌគតិយុត្តផ្សេងៗ
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារគ្រប់ប្រភេទពាក់ព័ន្ធនឹងការទទួលស្គាល់គុណភាពអប់រំ ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ

41

- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន ។

**មាត្រាបី.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបួន.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបួន
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ខែ ឆ្នាំ ២០០៩

## រចនាសម្ព័ន្ធ គ.ឧ.ក

